# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៖ ១០២២

ចុះថ្ងៃទី ០១-១២-២០១០

សាលដីកា

លេខ ៖ ១៧ (ក្រ IV នរ)

ចុះថ្ងៃទី២៥-០១-២០១៣

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

បានបង្កើតឡើងតាមច្បាប់ ស្តីពីការចាត់តាំងសកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ បានបើកសវនាកាជាសាធារណៈនៅសាលសវនាការសាលាឧទ្ធរណ៍នាថ្ងៃទី២៥-០១-២០១៣ ដោយមានសមាសភាពដូចខាងក្រោម ៖

**ក្រុមប្រឹក្សាជំនុំជំរះ**

-លោក [redacted] ជាប្រធានក្រុមប្រឹក្សា

- លោក [redacted] ជាចៅក្រមប្រឹក្សា

- លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

- លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

- លោកស្រី [redacted]

ដើម្បីជំនុំជំរះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ១០២២ ចុះថ្ងៃទី០១-១២-២០១០ រវាង ៖

-ជនជាប់ចោទឈ្មោះ [redacted] គុលឡោះ ភេទប្រុស អាយុ ២៦ឆ្នាំ ជាតិខ្មែរ មុខរបរព្រឡាន ទីកន្លែងកំណើតនៅសង្កាត់ច្បារអំពៅ ខណ្ឌមានជ័យ រាជធានីភ្នំពេញ [redacted] ចំរេះទី១ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោ [redacted] (រ) ម្តាយឈ្មោះ [redacted]) នៅលើរទោសពីមុន គ្មាន ។

-ឃុំខ្លួនថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៩ តាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ២៧៨៦ ត.ព្រ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ។

-មេធាវី នូ ចន្ថា ការពារសិទ្ធិឲ្យជនជាប់ចោទ ។

**ត្រូវចោទពីបទ ៖** [redacted] (ឆក់ខ្សែក) ប្រព្រឹត្តនៅផ្ទះលេខ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី០១-១១-២០០៩ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋចុះថ្ងៃទី០៧-០១-២០០៩ ។

-ជនរងគ្រោះឈ្មោះ [redacted] សម្ផស្ស ភេទស្រី អាយុ ១៨ឆ្នាំ ជាតិខ្មែរ មុខរបរសិស្ស ទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ៤៧ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

## ៦រឿងហេតុមានដូចតទៅ ៖

កាលពីថ្ងៃទី០១-១១-២០០៩ វេលាម៉ោង ១៨ :៤៥ នាទី មានករណីប្លន់ខ្សែកមួយកើតឡើង នៅចំណុចខាងកើតសួនកុមារវត្តភ្នំ ផ្លូវលេខ១៩ សង្កាត់វត្តភ្នំ ដោយមានជនជាប់ចោទឈ្មោះ [redacted] លឡោះ និងបក្សពួកមួយក្រុមប្រហែល ១០នាក់ បានដើរមកជិតជនរងគ្រោះឈ្មោះ [redacted] សម្ផស្ស ហើយធ្វើសកម្មភាពឆក់ខ្សែកប្លាទីនពីជនរងគ្រោះបានសម្រេច រួចនាំគ្នារត់គេចខ្លួន ក្នុងខណៈពេលនោះជនរងគ្រោះបានស្រែកឆោឡោឡើង ហើយកំលាំងសមត្ថកិច្ចបានធ្វើអន្តរាគមន៍ដេញចាប់បានជនជាប់ចោទម្នាក់ឈ្មោះ [redacted] គុលឡោះ នាំមកអធិការដ្ឋាននគរបាលខណ្ឌដូនពេញតែម្តង ។

-បានឃើញ សេចក្តីសំរេចរបស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចតាមអំណាចសាលក្រមលេខ ៦០ ក្រ៦ "ប" ចុះថ្ងៃទី០៨-០៩-២០១០ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ផ្តន្ទាទោសលើឈ្មោះ [redacted] គុលឡោះ ភេទប្រុស អាយុ ២៦ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ០៦ ឆ្នាំ (ប្រាំមួយឆ្នាំ) ។

ពីបទៈ ប្លន់ (ឆក់ខ្សែក) ប្រព្រឹត្តនៅផ្ទះលេខ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី០១-១១-២០០៩ បទល្មើសដែលមានចែងបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ចុះថ្ងៃទី០៧-០១-២០០១ ។

២-ទុកសិទ្ធិឲ្យឈ្មោះ [redacted] សម្ផស្ស ប្តឹងទាមទារសំណងរដ្ឋប្បវេណីតាមច្បាប់ ។

៣-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី២០-៧-២០១០ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៨-០៩-២០១០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] គុលឡោះ និងកំបាំងមុខជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សម្ផស្ស ។ ប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

-បានឃើញ ពាក្យបណ្តឹងលេខ ៦១៦ ចុះថ្ងៃទី១៣ -៩-២០១០ របស់ឈ្មោះ [redacted] គុលឡោះ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៦០ ក្រ៦ "ប" ចុះថ្ងៃទី០៨-៩-២០១០ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។

**-បានឃើញ** សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍។

**-បានឃើញ** របាយការណ៍រឿងព្រហ្មទណ្ឌរបស់ចៅក្រមរបាយការណ៍នៃសាលាឧទ្ធរណ៍។

## នាពេលសវនាការ

- ជនជាប់ចោទឈ្មោះ [redacted] **គុលឡោះ** (វត្តមាន)
- មេធាវីលោក [redacted] **ចន្ថា** ការពារសិទ្ធិអោយជនជាប់ចោទ (វត្តមាន)
- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សម្ផស្ស** (អវត្តមាន)

ប្រធានក្រុមប្រឹក្សាអានរបាយការណ៍សង្ខេបនៃរឿងក្តីៈ

- ជនជាប់ចោទឈ្មោះ [redacted] គុលឡោះ បានឆ្លើយថា ៖ ខ្លួនមិនបានសុខចិត្តចំពោះសាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចដាក់ពន្ធនាគារខ្លួនចំនួន ៦ឆ្នាំ ព្រោះពេលខ្លួនកំពុងញ៉ាំស្រា នៅជិតនោះ ប៉ូលីសបានចាប់ក្មេងម្នាក់ដែលបានឆក់ខ្សែកគេ ពេលនោះខ្លួនក៏បានទៅមើល និងសួរប៉ូលីសថា

មានរឿងអ្វីព្រោះក្មេងនោះភូមិជាមួយខ្លួន ហើយប៉ូលីសនោះក៏ចាប់ខ្លួន ហើយព្រលែងក្មេងនោះវិញ ពេលប៉ូលីសចាប់ខ្លួនអត់មានរបស់អ្វីនៅខ្លួនទេ ។ សំណូមពរ សុំលោកតុលាការមេត្តាលើកលែងទោសដល់រូបខ្លួនបាទផង ។

**-តំណាងមហាអយ្យការធ្វានធ្វើការសន្និដ្ឋានថា៖**

ក្រោយពីបានស្តាប់របាយការណ៍ និងការសួរដេញដោលមកឃើញថា ជនជាប់ចោទឈ្មោះ [redacted] **តុលឡោះ** បានប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៦០ ក្រ៦ "ប" ចុះថ្ងៃ០៨-៩-២០១០ គ្រប់ចំណុចសេចក្តីសម្រេចទាំងមូល ធ្វើឡើងក្នុងកំណត់ច្បាប់យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ជនជាប់ចោឈ្មោះ[redacted]**តុលឡោះ** បានឆ្លើយបដិសេធថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់របស់តំណាងអយ្យការទេ ។ ផ្អែកតាមចម្លើយជនរងគ្រោះ និងចម្លើយសាក្សី [redacted] **រដ្ឋា** មានភាពស៊ីសង្វាក់គ្នាថា នៅថ្ងៃកើតហេតុមានមនុស្សមួយក្រុមមានគ្នាប្រហែលជា ១០នាក់ បានធ្វើសកម្មភាពឆក់យកខ្សែកបានសម្រេច ពេលនោះមានកម្លាំងសមត្ថកិច្ចប្រចាំការក្បែរនោះធ្វើអន្តរាគមន៍ចាប់បានជនល្មើសម្នាក់បញ្ជូនមកនគរបាលខណ្ឌដូនពេញ ។ មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] តុលឡោះ ពីបទ: ប្លន់ ដូចការចោទប្រកាន់របស់អយ្យការ ។ សាលក្រមព្រហ្មទណ្ឌលេខ ៦០ ក្រ៦ "ប" ចុះថ្ងៃទី០៨-៩-២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចត្រឹមត្រូវហើយគប្បីតម្កល់ទុកជាបានការ ។

**-លោក [redacted]ចន្ថា មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋាន ៖** ក្រោយពីបានស្តាប់របាយការណ៍ ក្រោយពីបានស្តាប់ការសួរដេញដោល និងសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការមកក្នុងនាមខ្ញុំជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] តុលឡោះ ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ១០២២ ចុះថ្ងៃទី០១-១១-២០១០ របស់សាលាឧទ្ធរណ៍ ខ្ញុំសុំធ្វើសេចក្តីសន្និដ្ឋានការពារក្នុងរឿងនេះ កូនក្តីខ្ញុំឈ្មោះ [redacted] តុលឡោះ បានឆ្លើយនៅគ្រប់ដំណាក់ការសួរយកចម្លើយទាំងអស់ គឺកូនក្តីខ្ញុំឆ្លើយថាមិនបានឆក់ខ្សែកពីជនរងគ្រោះឈ្មោះ [redacted]សម្ផស្ស ទេ បើពិនិត្យចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីថាអ្នកឆក់មានគ្នា ១០នាក់ ហើយដើមបណ្តឹង និងសាក្សី គឺជាបងប្អូនជីដូនមួយគ្នា ។ ប៉ូលីសបានឃាត់កូនក្តីខ្ញុំភ្លាមៗដោយគ្មានភស្តុតាង មុននោះគឺប៉ូលីសចាប់បានឈ្មោះ អាលី ([redacted]លី) សុំប្រធានក្រុមប្រឹក្សា និងក្រុមប្រឹក្សាមេត្តាលើកយកមាត្រា ១១០ និង ១១៨ មកពិចារណា កូនក្តីខ្ញុំបានឆ្លើយបដិសេធរហូតគឺកូនក្តីខ្ញុំមិនបានប្រព្រឹត្តដូចការចោទប្រកាន់ តាមមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ វិមតិសង្ស័យត្រូវបានជាប្រយោជន៍ទៅលើកូនក្តីខ្ញុំ ។ សំណូមពរ សុំប្រធានក្រុមប្រឹក្សា និងក្រុមប្រឹក្សាសម្រេចឲ្យកូនក្តីខ្ញុំបានរួចផុតពីបទចោទប្រកាន់នេះផង ។

-ក្រោយពីបានស្តាប់របាយការណ៍រឿង

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងឯកសារនានា

-ក្រោយពីបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

## សាលាឧទ្ធរណ៍
## យល់ឃើញថា ៖

១-បណ្តឹងឧទ្ធរណ៍លេខ ៦១៦ ចុះថ្ងៃទី១៣-៩-២០១០ របស់ជនជាប់ចោទឈ្មោះ[redacted]គុលឡោះ ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌសាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន។

-មេធាវី[redacted]ចន្ថា ការពារសិទ្ធិឲ្យជនជាប់ចោទ ។

២-ថ្ងៃទី០១-១១-២០០៩ ម៉ោង ១៨:៤៥នាទី នៅសួនកុមារវត្តភ្នំ សង្កាត់វត្តភ្នំ នៅពេលជនរងគ្រោះ ឈ្មោះ [redacted]សម្ផស្ស ស្រែកចោរៗ ឈ្មោះ[redacted]រដ្ឋា អ្នកយាមម៉ូតូបានទៅជួយត្រូវក្រុមចោរប្រហែល ១០នាក់ ព្រួតវាយពេលនោះសមត្ថកិច្ចបានទៅជួយចាប់បានឈ្មោះ [redacted] គុលឡោះ នៅកន្លែងកើតហេតុ ។ [redacted] **គុលឡោះ** ដោះសារថាខ្លួនមិនមែនជាអ្នកឆក់ខ្សែទេ គ្រាន់តែចូលទៅសួរនាំពីរឿងហេតុតែប៉ុណ្ណោះ ប៉ុន្តែពុំមានភស្តុតាងដោះបន្ទុកលើឈ្មោះ នេះទេ។ ដូចនេះឈ្មោះ[redacted]គុលឡោះ ជាអ្នកប្រព្រឹត្តជាក់ស្តែង ។

៣-សាលក្រមព្រហ្មទណ្ឌលេខ ៦០ ក្រ៦ (ប) ចុះថ្ងៃទី០៨-៩-២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ។

## ហេតុដូចនេះ
## វិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ៦១៦ ចុះថ្ងៃទី១៣-៩-២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] គុលឡោះ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់គតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៦០ ក្រ៦ (ប) ចុះថ្ងៃទី០៨-៩-២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ។

៣-បន្តឃុំខ្លួនជនជាប់ចោទ តាមនីតិវិធី ។

៤-សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ មេធាវីលោក [redacted]ចន្ថា ការពារសិទ្ធិជនជាប់ចោទ ។ បើកផ្លូវប្តឹងសាទុក្ខ តាមកំណត់ច្បាប់ ។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកំលាំងប្រដាប់អាវុធជួយសហការ អនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| ក្រឡាបញ្ជី | ចៅក្រុមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted], [redacted] | [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី ០៦ ខែ [illegible] ឆ្នាំ២០១៤

ប្រធានស្តីទីសាលាឧទ្ធរណ៍

[redacted]

ក្រឡាបញ្ជី

[redacted]